**ឯកសារស្រាវជ្រាវ**

គណៈកម្មការទី៨ ព្រឹទ្ធសភា ទទួលបន្ទុកសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី

# បរិយាប័ន្នហិរញ្ញវត្ថុរបស់ស្ត្រីក្នុងការអភិវឌ្ឍប្រកបដោយចីរភាព៖ ពិនិត្យមើលឧបសគ្គដែលស្ត្រីជួបប្រទះនៅកម្ពុជា


ស្រាវជ្រាវដោយ៖ លោកស្រី រស់ បណ្ដែត

ដោយមានការចូលរួមពី៖ លោកស្រី តុប ដារី

លោក សែម វ៉ែន



ខែមីនា ឆ្នាំ២០១៧

**វិទ្យាស្ថានសភាកម្ពុជា**

# កំណត់សម្គាល់

វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក)គឺជាស្ថាប័នឯករាជ្យមួយដែល ផ្តល់ការគាំទ្រដល់សភាកម្ពុជា តាមរយៈការផ្តល់នូវឯកសារស្រាវជ្រាវទៅតាមសំណើរបស់សមាជិក-សមាជិកា និងគណៈកម្មការជំនាញរបស់រដ្ឋសភា-ព្រឹទ្ធសភា ដែលមានការវិភាគទៅលើបញ្ហាដែលកំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើងនាពេលអនាគត លើប្រធានបទការរៀបចំច្បាប់ និងគោលនយោបាយសាធារណៈ។ ឯកសារទាំងនេះផ្តល់នូវព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌល ឬភូមិភាគរបស់សមាជិក-សមាជិការសភា ក៏ប៉ុន្តែ រាល់អត្ថន័យដែលមាននៅក្នុងឯក-សារទាំងនេះមិនមែនតំណាង ឬឆ្លុះបញ្ចាំងអំពី ទស្សនៈផ្ទាល់របស់វិទ្យាស្ថានសភាកម្ពុជា សភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ។

ខ្លឹមសារនៃឯកសារទាំងនេះមានកំណត់នូវកាលបរិច្ឆេទរៀបចំច្បាស់លាស់ និងអាចប្រើប្រាស់សម្រាប់តែជាឯក.សារយោងប៉ុណ្ណោះ។ ឯកសារទាំងនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬទៅលើគោលនយោបាយណាមួយឡើយ ហើយក៏មិនបានធ្វើការសិក្សាអោយបានគ្រប់ប្រធានបទ ឬរាល់ខ្លឹមសារលម្អិតដែលពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនោះដែរ។

ខ្លឹមសារនៃឯកសារស្រាវជ្រាវនេះស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំឡើងវិញដោយដកស្រង់នូវផ្នែកណាមួយ ឬខ្លឹមសារទាំងស្រុងនៃឯកសារស្រាវជ្រាវនេះ ត្រូវមានការអនុញ្ញាតពីវិទ្យាស្ថាន។

រក្សាសិទ្ធិ ឆ្នាំ២០១៧ វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) ។

# មាតិកា

**១. សេចក្តីផ្តើម** ..... 1
**២. ស្ថានភាពបច្ចុប្បន្ននៃបរិយាប័ន្នហិរញ្ញវត្ថុរបស់ស្ត្រី** ..... 2
២.១. ស្ថានភាពទូទៅរបស់ស្ត្រីក្នុងសកម្មភាពសេដ្ឋកិច្ច ..... 2
២.២. ស្ថាប័នធនាគារ និងហិរញ្ញវត្ថុនៅកម្ពុជា ..... 2
២.៣. ក្រុមហ៊ុនផ្ទេរប្រាក់ ..... 3
២.៤. ការទទួលបានគណនី ការសន្សំ និងកម្ចី ..... 4
២.៥. លទ្ធភាពរបស់សហគ្រាសខ្នាតតូច និងមធ្យម ដែលជាកម្មសិទ្ធិរបស់ស្ត្រី ក្នុងការទទួលបានសេវាឥណទាន ..... 6
**៣. ឧបសគ្គរារាំងបរិយាប័ន្នហិរញ្ញវត្ថុរបស់ស្ត្រី** ..... 7
៣.១. លទ្ធភាពប្រើប្រាស់ និងលទ្ធភាពទទួលបានសេវាកម្មហិរញ្ញវត្ថុ ..... 8
៣.២. ការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុនៅក្នុងគ្រួសារ ..... 8
៣.៣. ការទូទាត់សង ..... 9
**៤. គោលនយោបាយ និងយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលក្នុងការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុរបស់ស្ត្រី** ..... 10
**៥. សន្និដ្ឋាន** ..... 11
**៦ឯកសារយោង** ..... 13

# ១. សេចក្ដីផ្ដើម

បរិយាប័ន្នហិរញ្ញវត្ថុ សំដៅលើដំណើរការក្នុងការសម្រេចបានជាសកលសម្រាប់មនុស្សគ្រប់រូបនូវការទទួលបាន សេវាហិរញ្ញវត្ថុជាច្រើនប្រភេទក្នុងតម្លៃសមរម្យ។ សេវាហិរញ្ញវត្ថុមិនមែនមានត្រឹមតែសេវាធនាគារដូចជាៈ គណនី ឥណទាន ឬការសន្សំនោះទេ ប៉ុន្តែក៏មានដូចជាសេវាធានារ៉ាប់រង ប្រាក់បញ្ញើរ និងការផ្ដល់ប្រឹក្សាហិរញ្ញវត្ថុផងដែរ។[1] ដូចគ្នាដែរបរិយាប័ន្នហិរញ្ញវត្ថុរបស់ស្ត្រី គឺសំដៅលើភាពដែលស្ត្រីអាចទទួលបានផលិតផល និងសេវាហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធិភាពដើម្បីគាំទ្រដល់មុខជំនួញ និងតម្រូវការគ្រួសាររបស់ខ្លួន។[2]

នៅលើពិភពលោកនេះ ត្រូវបានគេប៉ាន់ប្រមាណថា "មានស្ត្រីម្នាក់ក្នុងចំនោមស្ត្រីបីនាក់ ឬមានស្ត្រីចំនួន ១.១កោដិនាក់" ដែលមិនអាចទទួលបានសេវាហិរញ្ញវត្ថុផ្លូវការបាន។[3] បរិយាប័ន្នហិរញ្ញវត្ថុរបស់ស្ត្រី គឺមានសារៈសំខាន់ក្នុងការលើកកម្ពស់សមភាព និងសុខុមាលភាពរបស់មនុស្ស។ ការស្រាវជ្រាវបានរកឃើញថា នៅពេលស្ត្រីទទួលបានសេវាហិរញ្ញវត្ថុផ្លូវការ បញ្ហាចំនួនប្រាំ[4] ដែលបានកំណត់នៅក្នុងការអភិវឌ្ឍប្រកបដោយចេរភាពអាចត្រូវបានដោះស្រាយ។[5] នៅពេលស្ត្រីទទួលបានសេវាហិរញ្ញវត្ថុផ្លូវការ ស្ត្រីនឹងមិនទទួលរងគ្រោះពីការខ្ចីបុលពីអ្នកចងការប្រាក់ឯកជន ឬប្រឈមនឹងការលួច ឬការបាត់បង់ប្រាក់សន្សំឡើយ។ ផ្ទុយទៅវិញ ស្ត្រីនឹងទទួលបានឱកាសក្នុងការចូលរួមសកម្មភាពសេដ្ឋកិច្ច ការគ្រប់គ្រង និងការសម្រេចចិត្តក្នុងការប្រើប្រាស់ហិរញ្ញវត្ថុដើម្បីផលប្រយោជន៍គ្រួសារ។[6]

រដ្ឋាភិបាលកម្ពុជា បានទទួលស្គាល់អំពីសារៈសំខាន់នៃបរិយាប័ន្នហិរញ្ញវត្ថុរបស់ស្ត្រី។ កម្ពុជាបានអំពាវនាវដល់គ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ ឲ្យកំណត់ទិសដៅឲ្យបានប្រសើរឡើង ក្នុងការជួយគាំទ្រផ្នែកហិរញ្ញវត្ថុដល់ស្ត្រីជា មេគ្រួសារ។[7] ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងនេះក្ដី បរិយាប័ន្នហិរញ្ញវត្ថុរបស់ស្ត្រី នៅតែជាបញ្ហាប្រឈមសម្រាប់ប្រទេសកម្ពុជា បើប្រៀបធៀបជាមួយនឹងប្រទេសផ្សេងទៀតនៅអាស៊ីអាគ្នេយ៍។[8] ឯកសារទស្សនាទាននេះ នឹងធ្វើការពន្យល់អំពីឧបសគ្គសំខាន់ៗ ដែលរារាំងការសម្រេចបាននូវបរិយាប័ន្នហិរញ្ញវត្ថុរបស់ស្ត្រីនៅកម្ពុជា។ ជាដំបូងឯក សារនេះ នឹងធ្វើការរៀបរាប់អំពីស្ថានភាពបច្ចុប្បន្ននៃបរិយាប័ន្នហិរញ្ញវត្ថុរបស់ស្ត្រី បន្ទាប់មកនឹងបង្ហាញអំពីឧបសគ្គមួយចំនួនដែលរារាំងស្ត្រីក្នុងការទទួលបានឥណទាន និងការសងបំណុល ហើយជាចុងក្រោយឯកសារនេះ នឹងសិក្សាពីគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលដោះស្រាយបញ្ហាបរិយាប័ន្នហិរញ្ញវត្ថុរបស់ស្ត្រី។

# ២. ស្ថានភាពបច្ចុប្បន្ននៃបរិយាប័ន្នហិរញ្ញវត្ថុរបស់ស្ត្រី

## *២.១. ស្ថានភាពទូទៅរបស់ស្ត្រីក្នុងសកម្មភាពសេដ្ឋកិច្ច*

កម្ពុជាមានប្រជាជនសរុបចំនួន ១៥លាន និង៤៧សែននាក់ នៅឆ្នាំ២០១៥ ហើយស្ត្រីមានចំនួន ៥១ភាគរយ នៃប្រជាជនសរុប។[9] ស្ត្រីដែលជាមេគ្រួសារមានតែ ១៥ភាគរយប៉ុណ្ណោះ ខណៈដែលបុរសជាមេគ្រួសារមានចំនួនរហូតដល់ ៨៥ភាគរយ នៅឆ្នាំ២០១៥។[10]

កម្លាំងពលកម្មដែលចូលរួមដោយស្ត្រីស្មើនឹង៤៩ភាគរយ នៃកម្លាំងពលកម្មសរុប ក្នុងឆ្នាំ២០១២។ ទោះបីជាអត្រាចូលរួមក្នុងកម្លាំងពលកម្មរបស់ស្ត្រីមានចំនួន ៨០ភាគរយ ទាបជាងបុរសបន្តិច បើប្រៀបនឹងអត្រាចូលរួមរបស់បុរស៨៩ភាគរយ សម្រាប់ក្រុមអាយុ១៥-៦៤ឆ្នាំ ប៉ុន្តែអត្រាចូលរួមកម្លាំងពលកម្មរបស់ស្ត្រីនៃក្រុមអាយុ ១៥-១៩ឆ្នាំ មានចំនួន ៦៦ភាគរយ ច្រើនជាងអត្រារបស់បុរស ៦៤ភាគរយ។[11]

ទោះបីជា ការចូលរួមរបស់ស្ត្រីក្នុងកម្លាំងពលកម្ម មានកម្រិតខ្ពស់ក៏ដោយ ស្ត្រីនៅតែធ្វើការងារដែលត្រូវការជំនាញទាប បើប្រៀបធៀបនឹងបុរស។ ស្ត្រី តិចជាង ៤ភាគរយ ប៉ុណ្ណោះ បានធ្វើការងារដែលត្រូវការកម្រិតជំនាញខ្ពស់ដូចជា៖ អ្នកគ្រប់គ្រង អ្នកជំនាញវិជ្ជាជីវៈ និងអ្នកបច្ចេកទេស អ្នកជំនាញវិជ្ជាជីវៈមធ្យម។[12] ស្ត្រីជាទូទៅធ្វើការក្នុង វិស័យធំៗបី៖ ១-កសិកម្ម ព្រៃឈើ និងជលផល ២-ជំនួញលក់ដុំ និងលក់រាយ និងសេវាកម្ម ៣-ផលិតកម្ម ដែលការងារនៅក្នុងវិស័យទាំងនេះមានដល់ទៅ ៨៩ភាគរយ នៃការងារសរុបរបស់ស្ត្រី។[13]

## *២.២. ស្ថាប័នធនាគារ និងហិរញ្ញវត្ថុនៅកម្ពុជា*

ស្ថាប័នធនាគារ និងហិរញ្ញវត្ថុនៅកម្ពុជារីកចម្រើនយ៉ាងឆាប់រហ័សទាក់ទងវិសាលភាព និងទ្រង់ទ្រាយនៃប្រតិបត្តិការ (មើលតារាងទី១)។ នៅត្រឹមឆ្នាំ២០១៦ កម្ពុជាមានធនាគារពាណិជ្ជចំនួន ៣៧ ធនាគារឯកទេស ១៥ ការិយាល័យតំណាង ធនាគារបរទេស ៧ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើពីសាធារណៈជន ៧ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៦៣ ប្រតិបត្តិករឥណទានជនបទ១៧០ ក្រុមហ៊ុនបញ្ចាំ១២ ក្រុមហ៊ុនក្រេឌីតប្យូរ៉ូកម្ពុជា (credit bureau company) ១ និងអាជីវករប្តូរប្រាក់ ២.២៦១។[14] ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (MFIs) ទាំងនោះ កំពុងបន្តពង្រីកប្រតិបត្តិការរបស់ពួកគេ ដោយបើកសាខាជាច្រើន ដំឡើងម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ(ATM) និង ផ្តល់សេវាទូទាត់តាមអេឡិចត្រូនិកដល់អតិថិជនរបស់ខ្លួនទូទាំងប្រទេស។[15] ក្រៅពីស្ថាប័នធនាគារ និងហិរញ្ញវត្ថុទាំងនេះ ស្ថាប័នធានារ៉ាប់រងក៏កំពុងរីកចម្រើនផងដែរ។

តារាងទី១: អេធីអិម(ATM) គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងធនាគារពាណិជ្ជ និងស្ថាប័នធានារ៉ាប់រងឆ្នាំ២០១៣-២០១៥

| | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|
| ធនាគារពាណិជ្ជ | ៣៥ | ៣៦ | ៣៦ |
| ធនាគារឯកទេស | ៩ | ១១ | ១១ |
| ការិយាល័យតំណាងធនាគារបរទេស | ៦ | ៧ | ៨ |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ | ៣៨ | ៣៩ | ៥៨ |
| ប្រតិបត្តិករឥណទានជនបទ | ៣៣ | ៣៨ | ១០៤ |
| អេធីអិម (ATMs) | ៨៦៥ | ១១៣៧ | ១៤១៦ |
| អេធីអិមធៀបនឹងនីតិជន ១០០ ០០០នាក់ | ៨ | ១១ | ១៣ |
| សាខាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ | ១២៧៩ | ១៣៨៣ | ១៦៣២ |
| សាខាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ | ៧៨៦ | ១៣១១ | ២១៨៦ |
| សាខាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់ធៀបនឹងយុវជន១០០ ០០០នាក់ | ២១ | ២៦ | ៣៦ |
| សាខាធនាគារពាណិជ្ជ | ៤៥២ | ៥៥៧ | ៦១៤ |
| សាខាធនាគារពាណិជ្ជធៀបនឹងនីតិជន ១០០ ០០០នាក់ | ៥ | ៦ | ៦ |
| ស្ថាប័នសាជីវកម្មធានារ៉ាប់រង | ១០ | ១០ | ១១ |

ស្ថិតិIMF ២០១៥ និងNBC ២០១៣, ២០១៤,២០១៥ របាយការណ៍ប្រចាំឆ្នាំ២០១៥ ភ្នំពេញ កម្ពុជា

## *២.៣. ក្រុមហ៊ុនផ្ទេរប្រាក់*

នៅប្រទេសកម្ពុជា ក៏មានក្រុមហ៊ុនផ្ទេរប្រាក់ឯកជនជាច្រើន ដែលគាំទ្រប្រតិបត្តិការសាច់ប្រាក់សម្រាប់ប្រជាពលរដ្ឋនៅតាមជនបទ។ បណ្តាញផ្ទេរប្រាក់ទាំងនោះមានភ្នាក់ងារផ្ទាល់ខ្លួននៅតាមភូមិ ដែលធ្វើអោយប្រជាពលរដ្ឋនៅជនបទ អាចប្រើប្រាស់បាន និងយ៉ាងឆាប់រហ័ស។ សេវារបស់ពួកគេមានភាពងាយស្រួល និងមិនតម្រូវឲ្យអតិថិជនមានគណនីនៅធនាគារឡើយ។ មិនត្រឹមតែសម្រាប់ប្រតិបត្តិការផ្ទេរប្រាក់នៅក្នុងស្រុកនោះទេ ក្រុមហ៊ុនមួយចំនួនក៏ផ្តល់សេវាផ្ទេរប្រាក់បញ្ញើជាលក្ខណៈអន្តរជាតិផងដែរ។ មានក្រុមហ៊ុនធំៗចំនួនប្រាំពីរ កំពុងប្រតិបត្តិការផ្ទេរសាច់ប្រាក់នៅក្នុងប្រទេសកម្ពុជាដូចជា វីង ស្មាតលុយ អ៊ីម៉ាន់នី ទ្រូម៉ាន់នី អាស៊ីវេលុយ ផ្ទេរប្រាក់តាមប្រព័ន្ធទូរសព្ទរបស់អេ អឹម ខេ និង លី ហួរ (មើលតារាងទី២)។[16]

តារាង២៖ ភ្នាក់ងារ និងអតិថិជនរបស់ក្រុមហ៊ុនផ្ទេរប្រាក់តាមទូរស័ព្ទចល័តនៅក្នុងប្រទេសកម្ពុជា

| ឈ្មោះក្រុមហ៊ុន | កាលបរិច្ឆេទចាប់ផ្តើម | ចំនួនភ្នាក់ងារ |
|---|---|---|
| វីង | ខែមករា ២០០៩ | ៥.០០០ |
| អ៊ីម៉ាន់នី | ខែមិនា ២០១៥ | ៤.៥០០ |
| ទ្រូម៉ាន់នី | ខែមករា ២០១៦ | ៥.០០០ |
| ផ្ទេរប្រាក់របស់អេ អឹម ខេ | ខែតុលា ២០១៤ | ២.៥០០ |
| អាស៊ីវេលុយ | ខែកុម្ភៈ ២០១៥ | ១.៦៥០ |
| លី ហួរ | ខែកុម្ភៈ ២០១៦ | ១.០០០ |

ប្រភព៖ ភ្នំពេញប៉ុស្តិ៍ចេញផ្សាយ ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ការប្រកួតប្រជែងតឹងតែងជាងមុនលើការផ្ទេរប្រាក់

## *២.៤. ការទទួលបានគណនី ការសន្សំ និងកម្ចី*

ទោះបីជាមានការកើនឡើងនូវចំនួនស្ថាប័នហិរញ្ញវត្ថុ ទិន្នន័យហ្វិនដិចសកល(Global Findex Database) បានបង្ហាញថា នៅឆ្នាំ២០១៤ ប្រជាពលរដ្ឋកម្ពុជាត្រឹមតែ ២២ភាគរយ ដែលមានអាយុច្រើនជាង១៥ឆ្នាំ មានគណនីនៅស្ថាប័នហិរញ្ញវត្ថុជាផ្លូវការ ៤ភាគរយមានគណនីសន្សំជាផ្លូវការ និង២៨ភាគរយ បានខ្ចីប្រាក់ជាផ្លូវការ។ បើប្រៀបធៀបជាមួយប្រទេសនៅក្នុងអាស៊ីអាគ្នេយ៍ ប្រទេសកម្ពុជាមានភាគរយទាបបំផុតនៃអ្នកដែលមានគណនី និងអ្នកដែលមានគណនីសន្សំផ្លូវការ ប៉ុន្តែមានភាគរយខ្ពស់បំផុតនៃអ្នកខ្ចីប្រាក់ជាផ្លូវការ (មើលតារាងទី៣)។[17]

តារាង៣៖ ប្រៀបធៀបការចែកចាយនៃចំនួនប្រជាជនដែលមានគណនី គណនីសន្សំជាផ្លូវការ និងគណនីខ្ចីជាផ្លូវការនៅទូទាំងប្រទេសនៅក្នុងបណ្តាប្រទេសអាស៊ីអាគ្នេយ៍

| | **គណនី (%អាយុ១៥+)** | **គណនីសន្សំជាផ្លូវការ (%អាយុ១៥+)** | **ខ្ចីប្រាក់ជាផ្លូវការ (%អាយុ១៥+)** |
|---|---|---|---|
| ប្រទេសកម្ពុជា | ២២ | ៤ | ២៨ |
| ប្រទេសវៀតណាម | ៣១ | ១៥ | ១៨ |
| ប្រទេសថៃ | ៧៨ | ៤១ | ១៥ |
| ប្រទេសម៉ាឡេស៊ី | ៨១ | ៣៤ | ២០ |
| ប្រទេសសិង្ហបុរី | ៩៦ | ៤៦ | ១៤ |

ប្រភព៖ WB 2014 . Financial Inclusion Data / Global Findex.

ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងឆ្នាំ២០១៤ ធនាគារជាតិនៃកម្ពុជា បានចេញពីរបាយការណ៍ដែលបង្ហាញថា ភាគយខ្ពស់ជាងទិន្នន័យហ្វិនដិចសកល។ របាយការណ៍ប្រចាំឆ្នាំរបស់ធនាគារជាតិនៃកម្ពុជា នៅក្នុងឆ្នាំ ២០១៤ បានអះអាងថា ៤២% នៃនីតិជនកម្ពុជាបានទទួលសេវាហិរញ្ញវត្ថុពីធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលក្នុងនោះរួមមានអតិថិជនតម្កល់ប្រាក់ ៣,៣លាននាក់ និងអតិថិជនខ្ចី ២,២លាននាក់ នៅឆ្នាំ២០១៤។[18] នៅឆ្នាំ២០១៥ ធនាគារជាតិនៃកម្ពុជាបានចេញរបាយការណ៍ពីការកើនឡើងដល់ ៥១% នៃនីតិជនកម្ពុជា ដែលបានទទួលសេវាហិរញ្ញវត្ថុពីធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលក្នុងនោះអតិថិជនតម្កល់ប្រាក់មានចំនួន ៤លាននាក់ និងអតិថិជនខ្ចីចំនួន ២,៥លាននាក់។[19] ទោះបីជាយ៉ាងណាក៏ដោយ ធនាគារជាតិនៃកម្ពុជា ពុំបានផ្តល់ទិន្នន័យបំបែកតាមយេនឌ័រទាក់ទងនឹងការទទួលបានសេវាហិរញ្ញវត្ថុឡើយ។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការផ្តល់សេវាហិរញ្ញវត្ថុសម្រាប់ប្រជាពលរដ្ឋនៅតាមជនបទ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួន (ទាហរណ៍៖ ក្រេឌីត និង AMK) បានបង្កើតផលិតផល និងសេវាកម្មជាច្រើន ដើម្បីគាំទ្រដល់អតិថិជនក្រីក្រនៅតាមជនបទ រួមមានទាំងស្ត្រី។ ឧទាហរណ៍ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងនោះបានបង្កើតប្រាក់កម្ចីសហគមន៍ ឬកម្ចីជាក្រុមដោយមិនចាំបាច់មានទ្រព្យបញ្ចាំ ប្រាក់កម្ចីអប់រំ ប្រាក់កម្ចីបន្ទាន់។ បើយោងតាមសមាគមន៍មីក្រូហិរញ្ញវត្ថុកម្ពុជា នៅត្រីមាសទី៤ក្នុងឆ្នាំ ២០១៦ មានអតិថិជនខ្ចីចំនួន១.៩២១.៩៥៦នាក់ និងអតិថិជនដាក់ប្រាក់បញ្ញើរ ១.៥៩៦.៨៦៣នាក់ ដែលបានប្រើប្រាស់សេវារបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។[20] នៅក្នុងប្រទេសកម្ពុជា ចាប់តាំងពីឆ្នាំ២០១៣មក ស្ត្រី គឺជាអ្នកដែលបានប្រើប្រាស់សេវារបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុច្រើនជាងគេ។ បើយោងតាមបណ្តាញផ្លាស់ប្តូរព័ត៌មានដែលប្រមូលទិន្នន័យពី ៣៧ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និង ៥អង្គការ បានបង្ហាញថា ស្ត្រីមានចំនួន៨០% (ស្ត្រី១.០០៦.៧០០នាក់) នៃអតិថិជនសរុបរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នៅក្នុងឆ្នាំ២០១៣។[21]

ក្រៅពីការផ្តល់សេវាសន្សំ និងសេវាឥណទាន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួនបានដំណើរការមីក្រូធានារ៉ាប់រងផងដែរ ជាឧទាហរណ៍៖ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំរើនបានប្រតិបត្តិការមីក្រូធានារ៉ាប់រង ដែលមនុស្សម្នាក់ត្រូវការចំណាយត្រឹមតែ ០.៦៥ដុល្លារ ក្នុងមួយខែ ដើម្បីធានាលើការចំណាយសម្រាកនៅមន្ទីរពេទ្យគ្រោះថ្នាក់រហូតដល់ពិការភាព និងការស្លាប់។[22]

## *២.៥. លទ្ធភាពរបស់សហគ្រាសខ្នាតតូច និងមធ្យម ដែលជាកម្មសិទ្ធិរបស់ស្ត្រី ក្នុងការទទួលបានសេវាឥណទាន*

យោងទៅតាមជំរឿនសេដ្ឋកិច្ចឆ្នាំ២០១១ អាជីវកម្មចំនួន ៥០៥.១៣៤ មានដំណើរការនៅប្រទេសកម្ពុជា ដែលមានបុគ្គលិកចំនួន ១.៦៧៦.២៦៣នាក់ ដែលក្នុងនោះស្ត្រីមានចំនួន ៦១,២ភាគរយ និងបុរសមានតែ ៣៨,៨ភាគរយ ប៉ុណ្ណោះ។ ក្នុងចំណោមអាជីវកម្មចំនួន ៥០៥.១៣៤ អាជីវកម្មដែលជាកម្មសិទ្ធិរបស់ស្ត្រីមានរហូតដល់ទៅ ៦៥,១ភាគរយ ខណៈដែលបុរសមានតែ ៣៤,៩ ភាគរយ ប៉ុណ្ណោះ។[23]

អាជីវកម្មដែលជាកម្មសិទ្ធិរបស់ស្ត្រីនៅក្នុងប្រទេសកម្ពុជាភាគច្រើន ជាអាជីវកម្មខ្នាតតូច (មានតែមនុស្សមួយម្នាក់) ដែលដំណើរការឡើងក្រៅផ្លូវការ ឬក៏មានបំណងត្រឹមតែបង្កើតប្រាក់ចំណូលសម្រាប់គ្រួសារប៉ុណ្ណោះ។ អាជីវកម្មដែលជាកម្មសិទ្ធិរបស់ស្ត្រីទាំងនោះភាគច្រើនផ្តោតលើវិស័យឧស្សាហកម្មមួយចំនួនប៉ុណ្ណោះ ជាពិសេសទាក់ទងនឹង ពាណិជ្ជកម្មលក់ដុំនិងលក់រាយ ការស្នាក់នៅនិងម្ហូបអាហារ ការផលិត និងសេវាកម្មផ្សេងទៀត (មើលតារាងទី៤)។[24]

តារាងទី៤៖ សកម្មភាពអាជីវកម្មបែងចែកតាមយេនឌ័រ

| សកម្មភាពអាជីវកម្ម | ចំនួនសហគ្រាស | | |
|---|---|---|---|
| | សរុប | ជាកម្មសិទ្ធិរបស់បុរស | ជាកម្មសិទ្ធិរបស់ស្ត្រី |
| ចំនួនសហគ្រាសសរុប | ៥០៥.១៣៤ | ១៧៦.១២៨ | ៣២៩.០០៦ |
| | ១០០% | ៣៤,៩% | ៦៥,១% |
| លក់ដុំនិងរាយ ជួសជុលម៉ូទ័ររថយន្តនិងម៉ូតូ | ២៨៩.១៣០ | ៧៣.៥១៦ | ២១៥.៦១៤ |
| | ៥៧,២% | ១៤,៦% | ៤២,៧% |
| ការស្នាក់នៅ និងសេវាកម្មម្ហូបអាហារ | ៦៩.៥៦៩ | ១៤.៦១២ | ៥៤.៩៥៧ |
| | ១៣,៨% | ២,៩% | ១០,៩% |
| ការផលិត | ៧៥.០៣១ | ៣៩.៩៨៨ | ៣៥.០៣ |
| | ១៤,៩% | ៧,៩% | ៦,៩% |
| សកម្មភាពផ្សេងៗ | ៧១.៤០៤ | ៤៨.០០២ | ២៣.៤០២ |
| | ១៤,១% | ៩,៥% | ៤.៦% |

ប្រភព៖ ក្រសួងផែនការ/វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ២០១១។ ជំរឿនសេដ្ឋកិច្ចកម្ពុជា ភ្នំពេញ កម្ពុជា

ការមិនទទួលបានឥណទាន នៅតែជាបញ្ហាចម្បងសម្រាប់សហគ្រាសខ្នាតតូច និងមធ្យមដែលជាកម្មសិទ្ធិរបស់ស្ត្រី។ ក្នុងចំណោម សហគ្រាសខ្នាតតូច និងមធ្យមនៅប្រទេសកម្ពុជាដែលជាកម្មសិទ្ធិរបស់ស្ត្រី មាន ៨៩ភាគរយ មិនបានប្រើប្រាស់សេវាហិរញ្ញវត្ថុពីគ្រឹះស្ថានហិរញ្ញវត្ថុណាមួយទេ ដោយសារតែពួកគេមិនមានលទ្ធភាពទទួលបានសេវាឥណទានទាំងនោះ។ ក្នុងចំណោម ១១ភាគរយ ដែលបានប្រើប្រាស់សេវាហិរញ្ញវត្ថុ មាន ៨ភាគរយ ទទួលបានសេវាហិរញ្ញវត្ថុមិនគ្រប់គ្រាន់ និង ៣ភាគរយ ទៀតទទួលបានសេវាហិរញ្ញវត្ថុគ្រប់គ្រាន់។ នៅប្រទេសកម្ពុជា ចំនួនសហគ្រាសខ្នាតតូច និងមធ្យមដែលជាកម្មសិទ្ធិរបស់ស្ត្រីដែលអាចទទួលបានសេវាហិរញ្ញវត្ថុ គឺនៅមានកម្រិតទាបបើប្រៀបធៀបនឹងប្រទេសដ៏ទៃទៀតនៅក្នុងតំបន់ ឧទាហរណ៍ ប្រទេសឥណ្ឌូនេស៊ី ហ្វីលីពីន និងប្រទេសវៀតណាម។ ប្រទេសវៀតណាម មានភាគរយសហគ្រាសខ្នាតតូច និងមធ្យមដែលជាកម្មសិទ្ធិរបស់ស្ត្រីក្នុងការទទួលបានសេវាហិរញ្ញវត្ថុគ្រប់គ្រាន់ខ្ពស់ជាងគេ (មើលតារាងទី៥)។[25]

តារាងទី៥៖ លទ្ធភាពទទួលបានសេវាកម្មហិរញ្ញវត្ថុដោយស្ត្រីជាម្ចាស់កម្មសិទ្ធិសហគ្រាសខ្នាតតូច និងមធ្យម ទូទាំងអាស៊ីអាគ្នេយ៍

| ប្រទេស | អ្នកមិនប្រើប្រាស់សេវាហិរញ្ញវត្ថុ | | អ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុ | |
|---|---|---|---|---|
| | មិនត្រូវការសេវាឥណទាន | មិនអាចទទួលសេវា | ទទួលសេវាមិនគ្រប់គ្រាន់ | ទទួលសេវាគ្រប់គ្រាន់ |
| កម្ពុជា | ៤៨% | ៤១% | ៨% | ៣% |
| ឥណ្ឌូនេស៊ី | ៣១% | ៤២% | ១៩% | ៨% |
| ហ្វីលីពីន | ៣៩% | ២៤% | ២២% | ១៦% |
| វៀតណាម | ២៥% | ២៩% | ២៦% | ២១% |

ប្រភព៖ WOMEN'S WORLD BANKING(2015). Access to finance of women-owned SMEs in Southeast Asia: an assessment of five countries.

# ៣. ឧបសគ្គរាំងបរិយាប័ន្នហិរញ្ញវត្ថុរបស់ស្ត្រី

ឧបសគ្គរាំងបរិយាប័ន្នហិរញ្ញវត្ថុរបស់ស្ត្រីអាចត្រូវបានពិភាក្សាទាក់ទងនឹងចំណុចទាំងបីដូចខាងក្រោម៖ (១)លទ្ធភាពប្រើប្រាស់ និងលទ្ធភាពទទួលបានសេវាកម្មហិរញ្ញវត្ថុ (២) ការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុនៅក្នុងគ្រួសារ និង (៣) ការទូទាត់សង។

## ៣.១. លទ្ធភាពប្រើប្រាស់ និងលទ្ធភាពទទួលបានសេវាកម្មហិរញ្ញវត្ថុ

ឧបសគ្គរាំងលទ្ធភាពប្រើប្រាស់ និងលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុអាចពាក់ព័ន្ធនឹងការផ្គត់ផ្គង់ និងតម្រូវការ។ ទោះបីជាទិន្នន័យបង្ហាញថា ៨០ភាគរយ នៃអ្នកដែលប្រើប្រាស់សេវារបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គឺជាស្ត្រីក៏ដោយ លទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុរបស់សហគ្រាសខ្នាតតូច និងមធ្យមដែលជាកម្មសិទ្ធិរបស់ស្ត្រីនៅមានកម្រិតនៅឡើយ។ គេបានរកឃើញថាសហគ្រាសខ្នាតតូច និងមធ្យមជាច្រើនដែលជាកម្មសិទ្ធិរបស់ស្ត្រី មិនមានលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុ ឬទទួលបានមិនគ្រប់គ្រាន់ដើម្បីបំពេញតាមសេចក្តីត្រូវការរបស់ខ្លួនឡើយ ដោយសារមូលហេតុ ៦យ៉ាងដូចខាងក្រោម៖[26]

- កង្វះខាតឯកសារដែលតម្រូវដោយធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (ឧ. របាយការណ៍ហិរញ្ញវត្ថុកំណត់ត្រារបស់ធនាគារ) ដើម្បីបង្ហាញពីសមត្ថភាពអាជីវកម្មរបស់ខ្លួនក្នុងការទូទាត់សង។
- កង្វះទ្រព្យបញ្ចាំដូចជា ដីធ្លី អាគារ ឬប្រាក់បញ្ញើរមានជាឈ្មោះរបស់អតិថិជនខ្ចី។
- ការចំណាយខ្ពស់ក្នុងការស្វែងរកស្ថាប័នហិរញ្ញវត្ថុដែលល្អ ដោយសារការខាតបង់ពេលវេលា និងបាត់បង់ប្រាក់ចំណូលដោយសារតែការអវត្តមានពីអាជីវកម្មរបស់ខ្លួន។
- តម្រូវការឯកសារខ្ពស់។
- កង្វះខាតបណ្តាញសម្រាប់ប្រមូលព័ត៌មានទាក់ទងនឹងជម្រើសសេវាកម្មហិរញ្ញវត្ថុ ឬទទួលការគាំទ្រពីសហគ្រាសខ្នាតតូច និងមធ្យមជាច្រើន ដែលជាកម្មសិទ្ធិរបស់ស្ត្រីផ្សេងទៀត។
- អត្រាការប្រាក់ខ្ពស់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បើទោះបីជាអត្រានេះបានធ្លាក់ចុះពី ៥ភាគរយមកត្រឹម ២.៥ភាគរយ ក៏ដោយ។

## ៣.២. ការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុនៅក្នុងគ្រួសារ

ទោះជាស្ត្រី គឺជាអ្នកដែលប្រើប្រាស់សេវារបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុភាគច្រើនក្តី ប៉ុន្តែបើគិតពីបទដ្ឋានយេនឌ័រនៅប្រទេសកម្ពុជាវិញ វាមិនមែនមានន័យថាស្ត្រីជាអ្នកមានអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តក្នុងការគ្រប់គ្រងថវិកាដែលខ្ចីដោយប្រើប្រាស់ឈ្មោះរបស់ខ្លួននោះ។ ទោះបីជាទូទៅ គេតែងនិយាយថាបុរសជាអ្នករកចំណូល ចំណែកឯស្ត្រីជាអ្នកគ្រប់គ្រងហិរញ្ញវត្ថុនៅក្នុងផ្ទះក៏ដោយ ធាតុពិត អំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តរបស់ស្ត្រីជាទូទៅនៅមានកម្រិត។[27] ការសិក្សាមួយចំនួនបានរកឃើញថាអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តរបស់ស្ត្រីក្នុងការគ្រប់គ្រងថវិកា មានកម្រិតត្រឹមការទិញម្ហូប និងសំលៀកបំពាក់ប្រចាំថ្ងៃតែប៉ុណ្ណោះ ប៉ុន្តែមិនអាចសម្រេចចិត្តទៅលើការចំណាយធំៗទេ។[28] ទោះបីជានៅ

ក្នុងគ្រួសារខ្លះ បុរសស្វែងរកការពិគ្រោះយោបល់ជាមួយស្ត្រីក៏ដោយ ក៏បុរសនៅតែជាអ្នកផ្តើមគំនិត និងជាអ្នកធ្វើសេចក្តីសម្រេចចិត្តចុងក្រោយដែរ។[29]

### ៣.៣. *ការទូទាត់សង*

លទ្ធភាពអាចប្រើប្រាស់សេវាកម្មហិរញ្ញវត្ថុ ជាកត្តាមួយដែលជួយជម្រុញឲ្យមានបរិយាប័ន្នហិរញ្ញវត្ថុ ប៉ុន្តែការទូទាត់សង ក៏ជាកត្តាមួយផ្សេងទៀតដែលត្រូវពិចារណាប្រសិនបើយើងនិយាយពីបរិយាប័ន្នហិរញ្ញវត្ថុរបស់ស្ត្រី ដើម្បីសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចេរភាព។ ទោះបីជានៅកម្ពុជា អត្រាទូទាត់សងមានកម្រិតខ្ពស់ ពោលគឺ ៩៩ភាគរយ ក៏ដោយ គេរកឃើញថាអតិថិជនខ្ចីប្រាក់ជាច្រើន ជាទូទៅប្រឈមមុខទៅនឹងការលំបាកដ៏ខ្លាំងក្នុងការសងបំណុលឲ្យទាន់ពេលវេលា។ ទាក់ទងនឹងការទូទាត់សងបំណុល ស្ត្រីមានភាពងាយរងគ្រោះជាងបុរស។ ឧទាហរណ៍ Liv (2013) បានរកឃើញថា ២៤ភាគរយនៃអតិថិជនខ្ចីដែលមិនមានសមត្ថភាពទូទាត់សង ជាស្ត្រី ចំណែកឯបុរសមានតែ ៦ភាគរយ ប៉ុណ្ណោះ។[30]

ជាទូទៅវិធីសាស្ត្ររបស់អតិថិជនខ្ចីប្រាក់ដើម្បីដោះស្រាយការទូទាត់រួមមាន កាត់បន្ថយបរិមាណ និងគុណភាពអាហារ បញ្ជូនសមាជិកគ្រួសារឲ្យទៅធ្វើការនៅខាងក្រៅ ប្រើប្រាស់លុយសន្សំដើម្បីទូទាត់សង ខ្ចីប្រាក់កម្ចីបន្ថែម ធ្វើការបន្ថែមម៉ោង ពន្យាពេលការចំណាយលើសុខភាព លក់ ឬបញ្ចាំទ្រព្យ ឬបញ្ឈប់ការសិក្សារបស់កូន។ Liv (2013) បានចាត់ទុកថា ករណីការលះបង់ ឬការតស៊ូរបស់អតិថិជនខ្ចីប្រាក់ក្នុងការសងបំណុល ថាជាការជំពាក់ហួសសមត្ថភាព ដែលបណ្តាលមកពី មួយផ្នែក ពួកគេទទួលពហុកម្ចី ឬមួយផ្នែកទៀតដោយសារចំណេះដឹងខាងហិរញ្ញវត្ថុរបស់ពួកគេនៅមានកម្រិតនៅឡើយ។[31] ទិន្នន័យមកពី (CBC) បានបង្ហាញថា នៅត្រឹមខែឧសភា ឆ្នាំ២០១២ មានអតិថិជនខ្ចីចំនួន ១.២២៤.៣៦១នាក់ ដែលប្រើប្រាស់សេវាកម្មរបស់ស្ថាប័នផ្តល់កម្ចីផ្លូវការ។ ក្នុងចំណោមអតិថិជនខ្ចីទាំងនោះ ២១ភាគរយ ត្រូវបានគេរាយការណ៍ថាបានទទួលពហុកម្ចី ។[32] ទាក់ទងនឹងចំណេះដឹងខាងហិរញ្ញវត្ថុវិញ Live (2013) បានរកឃើញថា អតិថិជនខ្ចីប្រាក់ជាច្រើន មិនមានចំណេះដឹងគ្រប់គ្រាន់ដើម្បីគ្រប់គ្រងថវិកា ឬពិចារណារឿងចំណេញ ឬខាតទាក់ទងនឹងកម្ចីទេ។

## ៤. គោលនយោបាយ និងយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលក្នុងការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុរបស់ស្ត្រី

កម្ពុជាបានរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រជាច្រើន ដើម្បីលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ។ ចាប់តាំងពីការប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពី ធនាគារ និងស្ថាប័នហិរញ្ញវត្ថុ នៅចុងឆ្នាំ១៩៩៩ កម្ពុជាបានដាក់ចេញនូវក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ ដើម្បីគ្រប់គ្រងកំណើននៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា។ កម្ពុជាជាប្រទេសមួយក្នុងចំណោមបណ្តាប្រទេសនានាដែលធ្វើនិយ័តកម្មគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

- រហូតមកដល់ពេលបច្ចុប្បន្ននេះ ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយសំខាន់ៗដែលត្រូវបានដាក់ចេញ រួមមាន ការចុះបញ្ជី និងការផ្តល់សិទ្ធិធ្វើអាជីវកម្មដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ការគណនាអត្រាការប្រាក់ កាតព្វកិច្ចទុនបម្រុង កាតព្វកិច្ចរបាយការណ៍ សមាមាត្រសាច់ប្រាក់ទំនេររបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលទទួលបានសិទ្ធធ្វើអាជីវកម្ម ការបែងចែកប្រាក់កម្ចី និងការរៀបចំបញ្ញត្តិ និងការអនុវត្តតារាងគណនី។
- ប្រទេសកម្ពុជាក៏បានបង្កើតក្រេឌីតប្យូរ៉ូកម្ពុជានៅ ខែមិនា ឆ្នាំ២០១៣ ដើម្បីកាត់បន្ថយហានិភ័យឥណទានក្នុងការផ្តល់កម្ចី និងទុនដល់អាជីកម្ម និងអតិថិជនធម្មតា។
- កម្ពុជាបានដាក់ចេញនូវបច្ចេកវិទ្យាដើម្បីកែលម្អ ប្រសិទ្ធភាព និងការបន្ថយចំណាយក្នុងការទូទាត់សង ដោយប្រើប្រាស់ប្រព័ន្ធទូទាត់រហ័សនិងមានសុវត្ថិភាព នៅខែកក្កដា ឆ្នាំ២០១៥ ដើម្បីលើកកម្ពស់ ការប្រើប្រាស់ប្រាក់រៀល សម្រាប់ការផ្ទេរលុយរវាងគណនីពីធនាគារផ្សេងៗគ្នា។[33]
- ធនាគារជាតិនៃកម្ពុជា ជាមួយនឹងដៃគូរ Good Return Australia នៅឆ្នាំ២០១៦ បានធ្វើយុទ្ធនាការលើកម្ពស់ការយល់ដឹងអំពីហិរញ្ញវត្ថុរបស់អតិថិជន"ចូរពិភាក្សាអំពីថវិកា" ជាយុទ្ធនាការដើម្បីលើកកម្ពស់ការយល់ដឹងអំពីហិរញ្ញវត្ថុក្នុងចំណោមយុវជនខ្មែរ ។ នៅខែកុម្ភៈ ឆ្នាំ២០១៧ ធនាគារជាតិនៃកម្ពុជា ជាមួយដៃគូរ បានបោះពុម្ភសៀវភៅបែបកំប្លែងដែលមានចំណងជើង "ចូរពិភាក្សាអំពីថវិកា" ដើម្បីលើកកម្ពស់ការយល់ដឹងអំពីហិរញ្ញវត្ថុរបស់កុមារអាយុ ពី ៨ ទៅ ១២ ឆ្នាំ។[34]
- នៅខែកុម្ភៈ ឆ្នាំ២០១៧ នាយករដ្ឋមន្ត្រីបានដាក់ចេញនូវសេចក្តីណែនាំមួយដែលតម្រូវឲ្យធនាគារឯកជន និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រកាសថាស្ថាប័នខ្លួន ជារបស់ឯកជន និងតម្រូវឲ្យធនាគារមួយចំនួនផ្លាស់ប្តូរស្លាកសញ្ញា ដែលទាំងនេះត្រូវបានអនុវត្តដោយប្រកាសរបស់ធនាគារជាតិនៃកម្ពុជា លេខ ប១៣០១៧០៨៦ ដែលបានដាក់ចេញនៅ ខែកុម្ភៈ ដដែលនោះ។[35]

- នៅខែ មីនា ឆ្នាំ២០១៧ ធនាគារជាតិនៃកម្ពុជាបានកំណត់ពិដានអត្រាការប្រាក់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រឹម ១៨ភាគរយ ក្នុងមួយឆ្នាំ។[36]

គេបានរកឃើញថា គោលនយោបាយស្តីពីបរិយាប័ន្នហិរញ្ញវត្ថុពុំបានផ្តោតការយកចិត្តទុកដាក់គ្រប់គ្រាន់ទៅលើស្ត្រីទេ។ [37]

# ៥. សន្និដ្ឋាន

ការសិក្សានេះរកឃើញថាទិន្នន័យ និងព័ត៌មានបំបែកតាមយេនឌ័រ សម្រាប់វាយតម្លៃទៅលើស្ថានភាពបរិយាប័ន្នហិរញ្ញវត្ថុរបស់ស្ត្រីនៅមានកម្រិតនៅឡើយនៅប្រទេសកម្ពុជា។ ផ្អែកតាមទិន្នន័យដែលមានស្រាប់ ការសិក្សារកឃើញថាកម្ពុជាសម្រេចបានលទ្ធផលជាវិជ្ជមានមួយចំនួនទាក់ទងនឹងបរិយាប័ន្នហិរញ្ញវត្ថុរបស់ស្ត្រី ក្នុងនោះទាក់ទងនឹងវឌ្ឍនភាពរបស់ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដោយរួមទាំងភ្នាក់ងារផ្ទេរប្រាក់។ ច្បាស់ណាស់ ដោយសារវឌ្ឍនភាពរបស់ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនេះហើយ ទើបកម្ពុជាអាចជម្រុញឲ្យមានអត្រាភាគរយខ្ពស់នៃស្ត្រីក្នុងការទទួលបានគណនី ឥណទាន និងការសន្សំ។ មីក្រូហិរញ្ញវត្ថុនៅកម្ពុជាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ឥណទានទៅប្រជាជនក្រីក្រនៅតាមជនបទ ដោយរួមទាំងស្ត្រី តាមរយៈការផ្តល់កម្ចីក្រុម និងកម្ចីតូចមិនទាមទារទ្រព្យបញ្ចាំ កម្ចីអប់រំ កម្ចីបន្ទាន់ និងការផ្តល់មីក្រូធានារ៉ាប់រង ដោយរួមទាំងការធ្វើការងារផ្ទាល់ជាមួយប្រជាជន។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានលទ្ធភាពបញ្ជ្រៀតចូលទីជនបទក្នុងការផ្តល់សេវាទៅដល់ស្ត្រីងាយរងគ្រោះ។ រដ្ឋាភិបាលកម្ពុជាក៏បានចេញក្របខ័ណ្ឌច្បាប់ និងគោលនយោបាយដើម្បីជួយជម្រុញ និងលើកកម្ពស់ឲ្យប្រជាជនទទួលបានហិរញ្ញវត្ថុគ្រប់ៗគ្នាផងដែរ។

ទោះជាយ៉ាងណាក៏ដោយ កម្ពុជានៅតែស្ថិតនៅពីក្រោយប្រទេសផ្សេងៗនៅអាស៊ីអាគ្នេយ៍ទាក់ទងការផ្តល់ហិរញ្ញវត្ថុដល់សហគ្រាសដែលស្ត្រីជាម្ចាស់កម្មសិទ្ធិ។ កម្ពុជាក៏ប្រឈមផងដែរទាក់ទងលទ្ធភាពក្នុងការទូទាត់បំណុលពីសំណាក់ប្រជាជនដែលខ្ចីបុល ហើយស្ត្រីក៏ឋិតនៅក្នុងចំណោមនោះផងដែរ។ ច្បាស់ណាស់ថាកម្ពុជាមានអត្រាភាគរយច្រើននៃស្ត្រីដែលទទួលកម្ចីក្រោមឈ្មោះរបស់ខ្លួន ប៉ុន្តែវាមិនទាន់ច្បាស់ថាស្ត្រីទាំងនោះទទួលបានការសម្រេចចិត្តពេញលេញក្នុងការគ្រប់គ្រងកម្ចីនោះទេ។ មានចំនុចមួយចំនួនដែលត្រូវការឲ្យមានការដោះស្រាយដើម្បីជម្រុញឲ្យសម្រេចបានបរិយាប័ន្នហិរញ្ញវត្ថុរបស់ស្ត្រី ដូចជា៖

- ទីមួយ កម្ពុជាត្រូវកំណត់សូចនាករឲ្យបានច្បាស់ក្នុងការវាយតម្លៃស្ថានភាពបរិយាប័ន្នហិរញ្ញវត្ថុរបស់ស្ត្រី និងត្រូវរៀបចំឲ្យមានប្រព័ន្ធព័ត៌មាន និងទិន្នន័យបែងចែកតាមយេនឌ័រដើម្បីតាមដានស្ថានភាពស្ត្រី។

- គួរធ្វើការត្រួតពិនិត្យនីតិវិធីដែលកំណត់ដោយធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅក្នុងការផ្តល់ប្រាក់កម្ចីទៅឲ្យសហគ្រាសធនតូច និងមធ្យម ជាពិសេសសហគ្រាសដែលស្ត្រីជាម្ចាស់កម្មសិទ្ធិ។
- ធនាគារជាតិនៃកម្ពុជា អាចជួយតាមដានការជ្រៀតចូលទីផ្សារ របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាក់ទងការផ្តល់ពហុកំចីដល់ក្រុមងាយរងគ្រោះ ជាពិសេសស្ត្រី។
- ធនាគារជាតិនៃកម្ពុជា និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុគួរបន្តធ្វើការងារលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុដល់ស្ត្រី ជាពិសេសត្រូវធ្វើការសង្កត់ធ្ងន់ទៅលើហានិភ័យ និងគុណប្រយោជន៍ក្នុងការទទួលប្រាក់កម្ចី។

# ឯកសារយោង

[1] RANGARAJAN, C. 2008. Report of the committee on financial inclusion.
[2] GIZ December 2012. Promoting women's financial inclusion: a toolkit. Germany: GIZ.
[3] BIN-HUMAM, Y. 2017. *5 Challenges for Women's Financial Inclusion* [Online]. CGAP. Available: http://www.cgap.org/blog/5-challenges-women%E2%80%99s-financial-inclusion [Accessed 17 March 2017].
[4] បញ្ហាចំនួនប្រាំរួមមាន៖ ការលុបបំបាត់ភាពក្រីក្រ សន្តិសុខស្បៀង សុខភាពនិងសុខុមាលភាព ការអប់រំ និង សមភាពយេនឌ័រ។
[5] KLAPPER, L., EL-ZOGHBI, M. & HESS, J. 2016. Achieving the Sustainable Development Goals the Role of Financial Inclusion. *Washington, DC: CGAP*.
[6] Ibid.
[7] NBC 2007. Microfinance of Cambodia.
[8] WOMEN'SWORLDBANKING August 2015. Access to finance of women-owned SMEs in Southeast Asia: an assessment of five countries.
[9] 2015. Commune Data Base Cambodia.
[10] Ibid.
[11] NIS/MOP 2012. Cambodia Socio-Economic Survey. Phnom Penh, Cambodia.
[12] Ibid.
[13] NIS/MOP 2013. Cambodia inter-censal population survey. Phnom Penh, Cambodia.
[14] NBC 2016. Annual Report 2016. Phnom Penh, Cambodia.
[15] Ibid.
[16] PHNOMPENHPOST 8 November 2016. A tighter race to deliver money. Phnom Penh, Cambodia.
[17] WB 2014. *Financial Inclusion Data/Global Findex*.
[18] NBC 2014. Annual Report 2014. Phnom Penh, Cambodia.
[19] NBC 2015. Annual Report 2015. Phnom Penh, Cambodia.
[20] CMA. 2017. *Latest Data for Cambodian Microfinance* [Online].
[21] ASIAN DEVELOPMENT BANK 2015. *Promoting Women's Economic Empowerment in Cambodia*, O Books Sun & Moon.
[22] CHAMROEUN MICROFINANCE LIMITED. *Micro Insurance* [Online]. Available: http://www.chamroeun.com/page/micro-insurance.
[23] NIS/MOP 2011. Cambodia Economic Census. Phnom Penh, Cambodia.
[24] Ibid.
[25] ASIAN DEVELOPMENT BANK 2015. *Promoting Women's Economic Empowerment in Cambodia*, O Books Sun & Moon.
[26] Ibid.
[27] GADC 2010. Deoum Troung Pram Hath in Modern Cambodia: A Qualitative Exploration of Gender Norms, Masculinity and Domestic Violence Cambodia.
[28] BRICKELL, K. 2007. *Gender relations in the Khmer 'home': Post-conflict perspectives.* Degree of Doctor of Philosophy, University of London.
[29] Ibid.
[30] LIV, D. March 2013. Study on the Drivers of Over-Indebtedness of Microfinance Borrowers in Cambodia: An In-depth Investigation of Saturated Areas.
[31] Ibid.
[32] Ibid.
[33]NBC 2016. Annual Report 2016. Phnom Penh, Cambodia.
[34] NBC 2017. Press release on Let's Talk Money!
[35] NBC February 2017. Prakas on declaring Banks and MFIs as private institutions.
[36] NBC March 2017. Prakas on setting interest rate ceiling of microfinance.
[37] រហូតមកដល់ពេលបច្ចុប្បន្ននេះពុំមានគោលនយោបាយស្តីពីបរិយាប័ន្នហិរញ្ញវត្ថុដែលមានគោលដៅច្បាស់លាស់ក្នុងការដោះស្រាយលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុរបស់ស្ត្រីទេ។